ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ៤៧៣ ឧរថ.កសឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ មីនា ឆ្នាំ២០១១

# ប្រកាស

## ស្តីពី

## ការចុះបញ្ជីគំនូរបន្ទាញនៃសៀគ្វីបង្រួម

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្របក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្របក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣ស្តីពីការតម្លើងការិយាល័យកម្មសិទ្ធិឧស្សាហកម្មនៃនាយកដ្ឋានបច្ចេកទេស ទៅជានាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញប្រកាសលេខ ៤៨៧ ឧរថ.បល.ប្រក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- តាមការចាំបាច់របស់ក្រសួង



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣

45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

# សម្រេច

## ផ្នែកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- ការកំណត់លក្ខណៈរបស់ប្រកាស**

ប្រកាសនេះត្រូវចាត់ទុកជាបទបញ្ញាសម្រាប់ការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម នៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីការពារកម្មសិទ្ធិបញ្ញារបស់អ្នកបង្កើតស្នាដៃតក្កកម្មខាងផ្នែកគំនូរបង្ហាញនៃសៀគ្វីបង្រួម ។

**ប្រការ ២.- ភារកិច្ចរបស់នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មដែលជានាយកដ្ឋានទទួលបន្ទុកចុះបញ្ជី មានភារកិច្ចទទួលធ្វើការពិនិត្យពាក្យសុំចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម ធ្វើការចុះបញ្ជី និងគ្រប់គ្រងការចុះបញ្ជីនេះឱ្យមានប្រសិទ្ធភាព ។

## ផ្នែកទី ២

## និយមន័យ និង ការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម

**ប្រការ ៣.- និយមន័យ**

គំនូរបង្ហាញ សៀគ្វីបង្រួម ត្រូវបានកំណត់និយមន័យដូចខាងក្រោម :

១- **គំនូរបង្ហាញ** គឺការរៀបចំជាទម្រង់បីខ្នាតនៃធាតុដែលយ៉ាងហោចណាស់មានធាតុមួយជាធាតុសកម្ម ហើយភ្ជាប់ការទំនាក់ទំនងគ្នាទៅវិញទៅមកនៃធាតុមួយ ឬនៃធាតុមួយចំនួន ឬទាំងអស់នៃសៀគ្វីបង្រួម ឬការរៀបចំទម្រង់បីខ្នាតនោះដែលបានរៀបចំឡើងសម្រាប់សៀគ្វីបង្រួមមានគោលបំណងសម្រាប់ផលិត ។

២- **សៀគ្វីបង្រួម** គឺជាផលិតផលមួយក្នុងទម្រង់ជាផលិតផលសម្រេច ឬពាក់កណ្ដាលសម្រេចដែលក្នុងចំណោមធាតុជាច្រើន ដែលបង្កើតផលិតផលនោះដែលយ៉ាងហោចណាស់មានធាតុមួយជាធាតុសកម្ម ហើយបានបង្កើតឡើងនូវការភ្ជាប់គ្នាទៅវិញទៅមកនៃធាតុមួយចំនួន ឬទាំងអស់ដោយរួមបញ្ចូលគ្នានៅក្នុង ឬនៅលើវត្ថុមួយបន្ទះហើយមានគោលបំណងដំណើរការមុខងារផ្នែកអេឡិចត្រូនិច ។

**ប្រការ ៤.- អ្នកដាក់ពាក្យសុំ**

អ្នកដាក់ពាក្យសុំអាចស្នើសុំការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមតាមការស្ម័គ្រចិត្ត ។

**ប្រការ ៥.- គំនូរបង្ហាញនៃសៀគ្វីបង្រួមដែលអាចសុំចុះបញ្ជីបាន**

គំនូរបង្ហាញនៃសៀគ្វីបង្រួមអាចសុំចុះបញ្ជីបាន ប្រសិនបើគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះពុំទាន់ត្រូវបានយកទៅធ្វើអាជីវកម្មតាមទ្រង់ទ្រាយពាណិជ្ជកម្ម ឬក៏បានធ្វើអាជីវកម្មតាមទ្រង់ទ្រាយពាណិជ្ជកម្ម នៅទីកន្លែងណាមួយនៅលើពិភពលោកក្នុងរយៈពេលមិនលើសពី ២(ពីរ)ឆ្នាំ ។

**ប្រការ ៦.- លក្ខខណ្ឌនៃការចុះបញ្ជី**

គំនូរបង្ហាញនៃសៀគ្វីបង្រួមអាចចុះបញ្ជីបានប្រសិនបើគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះថ្មី ។

**ប្រការ ៧.- ភាពថ្មី**

គំនូរបង្ហាញនៃសៀគ្វីបង្រួមដែលអាចចាត់ទុកថាថ្មីបាន លុះត្រាតែគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះជាលទ្ធផលនៃការខិតខំប្រឹងប្រែងខាងប្រាជ្ញាផ្ទាល់របស់អ្នកបង្កើត និងដែលមិនមែនជាការងារសាមញ្ញធម្មតានៅក្នុងចំណោមអ្នកបង្កើតគំនូរបង្ហាញនៃសៀគ្វីបង្រួម និងនៅក្នុងចំណោមអ្នកផលិតសៀគ្វីបង្រួមទាំងឡាយ នៅពេលដែលបង្កើតគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះឡើង ។

**ប្រការ ៨.- សិទ្ធិចំពោះគំនូរបង្ហាញនៃសៀគ្វីបង្រួម**

សិទ្ធិចំពោះគំនូរបង្ហាញនៃសៀគ្វីបង្រួមមានដូចខាងក្រោម :

១- សិទ្ធិចំពោះគំនូរបង្ហាញនៃសៀគ្វីបង្រួម គឺជាសិទ្ធិរបស់អ្នកបង្កើតគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះ ។

២- សិទ្ធិនេះអាចប្រគល់ ឬផ្ទេរទៅឱ្យបុគ្គលដទៃដើម្បីស្នងជំនួសបាន ។

៣- ក្នុងករណីមានបុគ្គលច្រើននាក់បានបង្កើតគំនូរបង្ហាញនៃសៀគ្វីបង្រួមរួមគ្នា សិទ្ធិជាម្ចាស់នៃគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះត្រូវតែជាសិទ្ធិរួមគ្នានៃបុគ្គលទាំងឡាយនោះ ។

**ប្រការ ៩.- វិសាលភាពនៃការការពារ**

ការអនុវត្តសកម្មភាពដូចខាងក្រោមនេះ គឺជាសកម្មភាពមិនស្របច្បាប់ប្រសិនបើការអនុវត្តសកម្មភាពនោះពុំមានការអនុញ្ញាតពីម្ចាស់សិទ្ធិរួមមាន :

១- ការចម្លងតាមគំនូរបង្ហាញនៃសៀគ្វីបង្រួមទាំងស្រុង ឬផ្នែកណាមួយនៃគំនូរបង្ហាញនៃសៀគ្វីបង្រួមដែលបានការពាររួចហើយ ទោះបីបានរួមបញ្ចូលទៅក្នុងសៀគ្វីបង្រួម ឬមិនបានរួមបញ្ចូលលើកលែងតែសកម្មភាពចម្លងតាមផ្នែកណាមួយដែលផ្នែកនោះ មិនសមស្របតាមលក្ខខណ្ឌតម្រូវនៃភាពថ្មីដូចមានចែងនៅ



៥

ក្នុងប្រការ ៧ នៃប្រកាសនេះ ។

២-ការនាំចូល ការលក់ ឬការបែងចែកសម្រាប់ធ្វើពាណិជ្ជកម្មនូវសៀគ្វីបង្រួម ដែលបានការពាររួចហើយដោយគំនូរបង្ហាញនៃសៀគ្វីបង្រួម ឬសម្ភារៈដែលបង្កើតឡើងដោយមានការរួមបញ្ចូលនូវសៀគ្វីបង្រួមខាងលើ ដោយបុគ្គលដទៃក្រៅពីម្ចាស់សិទ្ធិត្រូវសុំការអនុញ្ញាតពីម្ចាស់សិទ្ធិ ។

**ប្រការ ១០.- ការលើកលែងពីអានុភាពនៃការការពារ**

អានុភាពនៃការការពារនៃគំនូរបង្ហាញនៃសៀគ្វីបង្រួមមិនអនុវត្តចំពោះសកម្មភាពដូចខាងក្រោម :

ក- ការចម្លងតាមគំនូរបង្ហាញនៃសៀគ្វីបង្រួមដែលបានការពាររួចហើយសម្រាប់បម្រើគោលបំណងផ្ទាល់ខ្លួន ឬបម្រើគោលបំណងសម្រាប់តែធ្វើការវាយតម្លៃ ការវិភាគ ការសិក្សា ស្រាវជ្រាវ ឬការបង្រៀនតែប៉ុណ្ណោះ ។

ខ- ការរួមបញ្ចូលនៅក្នុងសៀគ្វីបង្រួមនៃគំនូរបង្ហាញនៃសៀគ្វីបង្រួមដែលបានបង្កើតឡើងដោយឈរលើមូលដ្ឋានគ្រឹះនៃការវិភាគទាំងនេះ ឬការវាយតម្លៃហើយដែលគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះមានភាពថ្មីស្របតាមប្រការ ៥ នៃប្រកាសនេះ ឬការអនុវត្តនូវសកម្មភាពណាមួយចំពោះគំនូរបង្ហាញនៃសៀគ្វីបង្រួម ដោយយោងតាមប្រការ ៧ នៃប្រកាសនេះ ។

គ- ការអនុវត្តសកម្មភាពណាមួយនៃសកម្មភាពទាំងឡាយដូចមានចែងនៅក្នុងចំណុច ២ នៃប្រការ ៩ នៃប្រកាសនេះចំពោះគំនូរបង្ហាញនៃសៀគ្វីបង្រួមដែលបានការពាររួចហើយ ឬចំពោះសៀគ្វីបង្រួមដែលត្រូវបានរួមបញ្ចូលជាមួយគំនូរបង្ហាញនៃសៀគ្វី-បង្រួម ហើយដែលបានដាក់នៅលើទីផ្សារដោយម្ចាស់សិទ្ធិ ឬដោយមានការយល់ព្រមពីម្ចាស់សិទ្ធិនោះ ។

**ប្រការ ១១.- រយៈពេលនៃការការពារ**

ការការពារគំនូរបង្ហាញនៃសៀគ្វីបង្រួមត្រូវមានរយៈពេល ១០(ដប់)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមកិច្ចការពារ ។

ការចាប់ផ្តើមកិច្ចការពារត្រូវគិត :

ក- ចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី ប្រសិនបើគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះមិនទាន់បានធ្វើអាជីវកម្ម ពាណិជ្ជកម្មពីមុនមកនៅឡើយនៅទីកន្លែងណាមួយ ។

ខ- ចាប់ពីកាលបរិច្ឆេទធ្វើអាជីវកម្ម ពាណិជ្ជកម្មលើកដំបូងនៃគំនូរបង្ហាញ

នៃសៀគ្វីបង្រួមនោះនៅទីកន្លែងមួយដោយម្ចាស់សិទ្ធិ ឬដោយមានការយល់ព្រមពីម្ចាស់សិទ្ធិក្នុងរយៈពេលអនុញ្ញាតអាចសុំចុះបញ្ជីបានដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ។

**ប្រការ ១២.- លក្ខខណ្ឌតម្រូវនៃសំណុំលិខិតស្នើសុំ**

លក្ខខណ្ឌតម្រូវនៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម មានដូចខាងក្រោម :

១- សំណុំលិខិតស្នើសុំចុះបញ្ជីការពារគំនូរបង្ហាញនៃសៀគ្វីបង្រួមត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងត្រូវដាក់នៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ។ គំនូរបង្ហាញនៃសៀគ្វីបង្រួមនីមួយៗត្រូវតែធ្វើសំណុំលិខិតស្នើសុំដោយឡែកៗពីគ្នា ។

២- សំណុំលិខិតស្នើសុំត្រូវ :

**ក-** មានពាក្យសុំចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមដូចមាន ជូនភ្ជាប់ជាមួយ **ឧបសម្ព័ន្ធ** និងមានអធិប្បាយដោយសង្ខេប និងច្បាស់លាស់អំពីគំនូរបង្ហាញនៃសៀគ្វី-បង្រួមនោះ ។

**ខ-** បញ្ជាក់អំពីឈ្មោះ អសយដ្ឋាន សញ្ជាតិ និងអសយដ្ឋានស្នាក់នៅរបស់អ្នកដាក់ពាក្យសុំ ។

**គ-** ភ្ជាប់មកជាមួយនូវឯកសារចម្លង ឬគំនូរបង្ហាញនោះព្រមជាមួយនឹងព័ត៌មានបញ្ជាក់អំពីមុខងារអេឡិចត្រូនិចដែលសៀគ្វីបង្រួមនឹងយកទៅអនុវត្ត និងលិខិតប្រគល់សិទ្ធិប្រសិនបើមានការចាត់តាំងតំណាងរបស់អ្នកដាក់ពាក្យសុំ ។

**ឃ-** បញ្ជាក់អំពីកាលបរិច្ឆេទធ្វើអាជីវកម្ម ពាណិជ្ជកម្មលើកដំបូងនៃគំនូរបង្ហាញនៃសៀគ្វីបង្រួមនៅទីកន្លែងណាមួយនៅលើពិភពលោក ឬបញ្ជាក់ថាការធ្វើអាជីវកម្មនោះមិនទាន់ចាប់ផ្តើមនៅឡើយទេ ។

**ង-** ព័ត៌មានចាំបាច់ផ្សេងទៀតតាមការស្នើសុំរបស់មន្ត្រីកាន់កាប់បញ្ជី ។

**ប្រការ ១៣.- ការចុះកាលបរិច្ឆេទសុំចុះបញ្ជី**

ក្នុងករណីសំណុំលិខិតស្នើសុំមិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃប្រការ ១២ នៃប្រកាសនេះ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំអំពីកំហុសដែលមាន និងអញ្ជើញអ្នកដាក់ពាក្យសុំឱ្យមកកែកំហុសទាំងនោះក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ ។ ប្រសិនបើកំហុសទាំងនោះបានកែតម្រូវតាមពេលវេលាកំណត់រួច ហើយមន្ត្រីកាន់កាប់បញ្ជីត្រូវតែចុះនៅថ្ងៃដែល ទទួលការកែតម្រូវនោះ កាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំឱ្យតែនៅពេលដែលទទួល នោះសំណុំលិខិតស្នើសុំមានបង្ហាញ ឬបញ្ជាក់អំពីការស្នើសុំចុះបញ្ជី

គំនូរបង្ហាញនៃសៀគ្វីបង្រួម និងបញ្ជាក់ឱ្យដឹងនូវអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំហើយ និងមានភ្ជាប់មកជាមួយនូវឯកសារចម្លង ឬគំនូរបង្ហាញនៃគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះ ។ មន្ត្រីកាន់កាប់បញ្ជីត្រូវកំណត់នូវកាលបរិច្ឆេទសុំចុះបញ្ជី និងផ្តល់ព័ត៌មាននេះឱ្យអ្នកដាក់ពាក្យសុំបានដឹង ។ ប្រសិនបើកំហុសទាំងឡាយមិនបានធ្វើការកែលំអតាមពេលវេលាកំណត់ទេនោះ សំណុំលិខិតស្នើសុំនោះ ត្រូវចាត់ទុកថាមិនបានយកមកដាក់ឡើយ ។

**ប្រការ ១៤.- ការបង់កម្រៃសម្រាប់ចុះបញ្ជី**

សំណុំលិខិតស្នើសុំចុះបញ្ជីការពារគំនូរបង្ហាញនៃសៀគ្វីបង្រួមនីមួយៗ ត្រូវផ្អែកលើការបង់កម្រៃតាមការកំណត់នៃប្រកាសរួមរបស់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ប្រសិនបើមិនបានមកបង់កម្រៃក្នុងការសុំចុះបញ្ជីតាមកាលកំណត់ទេ សំណុំលិខិតស្នើសុំនោះត្រូវបានចាត់ទុកថាមិនបានយកមកដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីឡើយ ។

**ប្រការ ១៥.- ការបោះពុម្ពផ្សាយ ការប្តឹងជំទាស់ ការចុះបញ្ជី និងបញ្ជី**

ការបោះពុម្ពផ្សាយ ការប្តឹងជំទាស់ ការចុះបញ្ជី និងបញ្ជីសម្រាប់គំនូរបង្ហាញនៃសៀគ្វីបង្រួមត្រូវអនុវត្តដូចខាងក្រោម :

១- ក្នុងករណីដែលសំណុំលិខិតស្នើសុំបំពេញត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃប្រការ ១២ និង ១៤ នៃប្រកាសនេះរួច ហើយមន្ត្រីកាន់កាប់បញ្ជីត្រូវផ្សព្វផ្សាយព័ត៌មានចាំបាច់នៃសំណុំលិខិតស្នើសុំនោះនៅក្នុងព្រឹត្តិបត្រផ្លូវការមុនពេលចុះបញ្ជី ។

២- បុគ្គលដែលមានការពាក់ព័ន្ធអាចជូនដំណឹងទៅ មន្ត្រីកាន់កាប់បញ្ជីអំពីការជំទាស់របស់ខ្លួនចំពោះការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមតាមបែបបទដែលបានកំណត់ដោយឈរលើមូលដ្ឋាននៃការមិនបានបំពេញតាមលក្ខខណ្ឌណាមួយនៃ ប្រការ ៥, ៦, ៧, និង បទបញ្ញាពាក់ព័ន្ធក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃបន្ទាប់ពីបានចុះផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

៣- ក្នុងករណីមានការជំទាស់ មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនជាបន្ទាន់នូវព័ត៌មានជំទាស់ទៅអ្នកដាក់ពាក្យសុំចុះបញ្ជីតាមពេលវេលា ។ បន្ទាប់មកអ្នកស្នើសុំចុះបញ្ជីត្រូវផ្តល់ចម្លើយបញ្ជាក់ដោយផ្អែកលើមូលដ្ឋានទាំងឡាយ សម្រាប់ការចុះបញ្ជីរបស់ខ្លួនជូនមន្ត្រីកាន់កាប់បញ្ជីទៅតាមរយៈពេលដែលកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី ។ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានឆ្លើយតបតាមការកំណត់នោះទេត្រូវចាត់ទុកថា អ្នកដាក់ពាក្យសុំនោះបានបោះបង់ចោលការសុំចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមរបស់ខ្លួន ។

៤- ប្រសិនបើអ្នកដាក់ពាក្យសុំផ្តល់ចម្លើយបដិសេធទៅនឹងការជំទាស់នោះ មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់ចម្លើយមួយច្បាប់ទៅអ្នកដែលបានប្តឹងជំទាស់ ។ ប្រសិនបើភាគីម្ខាង

ឬភាគីទាំងសងខាងមានបំណងចង់ឱ្យមានសវនាការមន្ត្រីកាន់កាប់បញ្ជី ត្រូវរៀបចំឱ្យមានសវនាការនោះ ។ បន្ទាប់ពីបានស្តាប់ភាគីទាំងសងខាង និងពិចារណាលើពាក្យតវ៉ា មន្ត្រីកាន់កាប់បញ្ជីត្រូវសម្រេចថា គំនូរបង្ហាញនៃសៀគ្វីបង្រួមអាចដំណើរការចុះបញ្ជីបាន ឬបដិសេធការចុះបញ្ជី ។

**៥.** ប្រសិនបើគ្មានការជំទាស់រយៈពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានចុះផ្សាយក្នុងព្រឹត្តិបត្រផ្លូវការនោះទេមន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះ

**៦.** នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មត្រូវមានបញ្ជីសម្រាប់គំនូរបង្ហាញនៃសៀគ្វីបង្រួម ។ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាគំនូរបង្ហាញនៃសៀគ្វីបង្រួម ដែលបានចុះបញ្ជីនៅក្នុងបញ្ជីនេះនូវព័ត៌មានដូចខាងក្រោម :

- លេខ
- ចំណងជើង
- កាលបរិច្ឆេទទទួលពាក្យសុំ
- កាលបរិច្ឆេទសុំចុះបញ្ជី
- កាលបរិច្ឆេទលើកដំបូងក្នុងការយកគំនូរបង្ហាញនៃសៀគ្វីបង្រួមទៅធ្វើអាជីវកម្មនៅទីកន្លែងណាមួយនៅលើពិភពលោកប្រសិនបើមាន ។
- ឈ្មោះ និងអសយដ្ឋាន របស់ម្ចាស់សិទ្ធិ និង
- ចំណុចសំខាន់ៗផ្សេងទៀតដែលចាំបាច់ ។

**ប្រការ ១៦.- មោឃភាព**

ចំពោះមោឃភាព ត្រូវអនុវត្តដូចខាងក្រោម :

**១.** បុគ្គលដែលមានការពាក់ព័ន្ធអាចស្នើសុំឱ្យទុកជាមោឃៈនូវការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមចំពោះមូលហេតុដូចខាងក្រោម :

**ក.** គំនូរបង្ហាញនៃសៀគ្វីបង្រួមមិនត្រូវបានការពារនៅក្រោមប្រការ ៥, ៦, ៧ នៃប្រកាសនេះ ។

**ខ.** ម្ចាស់សិទ្ធិពុំមានសិទ្ធិចំពោះការការពារនៅក្រោមប្រកាសនេះ ។

**គ.** ក្នុងករណីដែលគំនូរបង្ហាញនៃសៀគ្វីបង្រួម ត្រូវបានយកទៅធ្វើអាជីវកម្ម ពាណិជ្ជកម្មនៅទីកន្លែងណាមួយនៅលើពិភពលោកមុនការដាក់សំណុំលិខិតស្នើសុំចុះបញ្ជី ហើយសំណុំលិខិតស្នើសុំនោះពុំបានយកមកដាក់ត្រឹមត្រូវតាមពេលវេលាកំណត់ដូចមាន

ចែងក្នុងប្រការ ៥ នៃ ប្រកាសនេះ ។

២-  ក្នុងករណីដែលមូលហេតុនៃមោឃភាពប៉ះពាល់តែមួយផ្នែក នៃគំនូរបង្ហាញនៃសៀគ្វីបង្រួមទេនោះ គឺផ្នែកនោះឯងតែប៉ុណ្ណោះដែលត្រូវបានចាត់ទុកជាមោឃៈ ។

៣-  សំណើសុំចាត់ទុកជាមោឃៈនូវការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមត្រូវតែសរសេរជាលាយ លក្ខណ៍អក្សរហើយដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជីដើម្បីពិនិត្យ និងសម្រេច ។ សំណើសុំចាត់ទុកជាមោឃៈ ត្រូវមានបញ្ជាក់អំពីមូលហេតុដែលធ្វើជាមូលដ្ឋានក្នុងការស្នើសុំឱ្យចាត់ទុកជាមោឃៈចំពោះការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះ ។

៤-  គំនូរបង្ហាញនៃសៀគ្វីបង្រួមដែលបានចុះបញ្ជីរួចហើយ ឬផ្នែករបស់គំនូរបង្ហាញនៃសៀគ្វីបង្រួមដែលត្រូវបានចាត់ទុកជាមោឃៈនោះ ត្រូវអស់សុពលភាពចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃកិច្ចការពារគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះ ។

**ប្រការ ១៧.- ភ្នាក់ងារ**

ភ្នាក់ងារធ្វើជាតំណាងសម្រាប់អ្នកដាក់ពាក្យសុំចុះបញ្ជី គំនូរបង្ហាញនៃសៀគ្វីបង្រួមត្រូវអនុវត្តដូចខាងក្រោម :

១-  ក្នុងករណីអ្នកដាក់ពាក្យសុំមានទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកដាក់ពាក្យសុំនោះអាចដាក់ពាក្យសុំដោយខ្លួនឯង ឬអាចចាត់ភ្នាក់ងារជាតំណាងសម្រាប់ដាក់ពាក្យសុំបាន និងដែលបានបំពេញតាមលក្ខខណ្ឌតម្រូវដែលបានកំណត់ ។

២-  ក្នុងករណីអ្នកដាក់ពាក្យសុំមានទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់នៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកដាក់ពាក្យសុំនោះត្រូវមានតំណាងភ្នាក់ងារដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលបានបំពេញតាមលក្ខខណ្ឌតម្រូវទាំងឡាយដែលបានកំណត់ ។

**ប្រការ ១៨.- ការរំលោភបំពាន**

ការអនុវត្តសកម្មភាពណាមួយដែលមិនស្របនឹងប្រការ ៨ នៃប្រកាសនេះត្រូវចាត់ទុកវាជាការរំលោភបំពាន ។

**ប្រការ ១៩.- ការដោះស្រាយទំនាស់**

ការដោះស្រាយទំនាស់ត្រូវអនុវត្តដូចខាងក្រោម :

១-  រាល់ទំនាស់ដែលកើតមានឡើងពាក់ព័ន្ធទៅនឹងការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមត្រូវប្តឹងតវ៉ាទៅមន្ត្រីកាន់កាប់បញ្ជីដើម្បីធ្វើការដោះស្រាយ ។

២-  នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ត្រូវបង្កើតយន្តការដោះស្រាយទំនាស់ពាក់

ព័ន្ធទៅនឹងការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមតាមការចាំបាច់ ។

**ប្រការ ២០.- កិច្ចសហការ**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មត្រូវសហការជាមួយអង្គការជាតិ និងអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធដើម្បីជំរុញការការពារកម្មសិទ្ធិឧស្សាហកម្ម និងអភិវឌ្ឍប្រព័ន្ធចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម ។

## ផ្នែកទី ៣

## អវសានប្បញ្ញត្តិ

**ប្រការ ២១.- សមត្ថកិច្ចអនុវត្ត**

អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម ប្រធានវិទ្យាស្ថាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម និងប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត មានភារកិច្ចអនុវត្តក្នុងក្របខណ្ឌសមត្ថកិច្ចរៀងៗខ្លួន ។

**ប្រការ ២២.- ប្រសិទ្ធភាព**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ_សែម

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជបណ្ឌិតសភាកម្ពុជា
- គណៈកម្មការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា
- គ្រប់អគ្គនាយកដ្ឋាន
- គ្រប់នាយកដ្ឋានសេនាធិការក្រសួង
- ដូចប្រការ ២១ "ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

**អគ្គនាយកដ្ឋានឧស្សាហកម្ម**

**នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម**

# ពាក្យសុំចុះបញ្ជីគំនូរបន្ទាញនៃសៀគ្វីបង្រួមកម្ពុជា

**(គំរូ ស.ប)**

យោងលេខ

| | |
|---|---|
| | **សម្រាប់មន្ត្រីកាន់កាប់បញ្ជី** |
| **សាមីជនដែលបានចុះហត្ថលេខានេះ ស្នើសុំ ចុះបញ្ជីគំនូរបន្ទាញនៃសៀគ្វីបង្រួមកម្ពុជា កម្មវត្ថុដូចខាងក្រោមនេះ:** | **កាលបរិច្ឆេទទទួល :** |
| | **លេខរបស់សំណុំលិខិតស្នើសុំ :** |
| | **កាលបរិច្ឆេទសុំចុះបញ្ជី :** |

**ប្រអប់លេខ ១**

**ចំណងជើងនៃគំនូរបន្ទាញ** :....................................................................................................

....................................................................................................

**ប្រអប់លេខ ២**

**អ្នកដាក់ពាក្យសុំ(ទោះបីមិនមែនជាអ្នកបង្កើតស្នាដៃក៏ដោយ)**សូមប្រើប្រអប់នេះសម្រាប់បញ្ជាក់ប្រាប់ពីអ្នកដាក់ពាក្យសុំ ឬអ្នកណាម្នាក់ក៏បាន នៅក្នុងចំណោមអ្នកទាំងនោះ ប្រសិនបើអ្នកដាក់ពាក្យសុំមានគ្នាច្រើន ។ ប្រសិនបើមានគ្នាលើសពីមួយនាក់ (ឬអង្គភាពស្របច្បាប់លើសពីមួយឡើងទៅ) ដែលជាប់ពាក់ព័ន្ធសូមបន្តទៅប្រអប់បន្ថែម ។

បុគ្គលក្នុងប្រអប់នេះគឺជា (គូសតែមួយប៉ុណ្ណោះ) : ☐ អ្នកដាក់ពាក្យសុំ និងជាអ្នកបង្កើតស្នាដៃ ☐ អ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ

ឈ្មោះ និង អាសយដ្ឋាន ....................................................................................................

....................................................................................................

លេខទូរស័ព្ទ (រួមទាំងលេខកូដតំបន់) :....................................................................................................

លេខទូរសារ:.................................................. អាសយដ្ឋានអ៊ីមែល:..................................................

សញ្ជាតិ :.................................................. ប្រទេសស្នាក់នៅ:..................................................

បុគ្គលក្នុងប្រអប់នេះគឺជា (គូសតែមួយប៉ុណ្ណោះ) : ☐ អ្នកដាក់ពាក្យសុំ និងជាអ្នកបង្កើតស្នាដៃ ☐ អ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ

ឈ្មោះ និង អាសយដ្ឋាន:....................................................................................................

..............................................................................................................................................................................................................

លេខទូរស័ព្ទ (រួមទាំងលេខកូដតំបន់):

លេខទូរសារ:.......................................................... អសយដ្ឋានអ៊ីម៉ែល:..........................................................................................

សញ្ជាតិ :.......................................................... ប្រទេសស្នាក់នៅ: ..........................................................................................

**ប្រអប់លេខ ៣**

**អ្នកបង្កើតស្នាដៃ** ត្រូវបំពេញក្នុងប្រអប់តូចដាច់ពីគ្នាទៅតាមបុគ្គលនីមួយៗ ។ ប្រសិនបើប្រអប់តូចទាំងពីរនោះពុំមានកន្លែងគ្រប់គ្រាន់ទេ សូមបន្តទៅ "ប្រអប់បន្ថែម" (បំពេញនៅទីនេះសម្រាប់បុគ្គលបន្ថែមម្នាក់ៗដូចគ្នា និងការបញ្ជាក់នៃសំណើទាំងនោះ ក្នុងប្រអប់តូចទាំងពីរខាងក្រោម) ឬប្រើ "សន្លឹកបន្ត"

បុគ្គលក្នុងប្រអប់នេះគឺជា (គូសតែមួយប៉ុណ្ណោះ) : ☐ អ្នកដាក់ពាក្យសុំ និងអ្នកបង្កើតស្នាដៃ ☐ អ្នកបង្កើតស្នាដៃតែប៉ុណ្ណោះ

ឈ្មោះ និង អសយដ្ឋាន :..........................................................................................................................................

..............................................................................................................................................................................................................

ប្រសិនបើបុគ្គលដែលបានបញ្ជាក់ក្នុងប្រអប់តូចនេះគឺជាអ្នកដាក់ពាក្យសុំ (ឬ អ្នកដាក់ពាក្យសុំ និងអ្នកបង្កើតស្នាដៃ) ចូរបញ្ជាក់ផងដែរនូវ :

សញ្ជាតិ :.......................................................... ប្រទេសស្នាក់នៅ:..........................................................................................

បុគ្គលក្នុងប្រអប់នេះគឺជា (គូសតែមួយប៉ុណ្ណោះ) : ☐ អ្នកដាក់ពាក្យសុំ និងអ្នកបង្កើតស្នាដៃ ☐ អ្នកបង្កើតស្នាដៃតែប៉ុណ្ណោះ

ឈ្មោះ និង អសយដ្ឋាន:..........................................................................................................................................

..............................................................................................................................................................................................................

ប្រសិនបើបុគ្គលដែលបានបញ្ជាក់ក្នុងប្រអប់តូចនេះគឺជាអ្នកដាក់ពាក្យសុំ (ឬ អ្នកដាក់ពាក្យសុំ និងអ្នកបង្កើតស្នាដៃ) ចូរបញ្ជាក់ផងដែរនូវ :

សញ្ជាតិ :.......................................................... ប្រទេសស្នាក់នៅ:..........................................................................................

**ប្រអប់លេខ ៤**

**ភ្នាក់ងារ (ប្រសិនបើមាន) ឬតំណាងរួម (ប្រសិនបើមាន) ។ អាសយដ្ឋានសម្រាប់ជូនដំណឹង (ក្នុងករណីចាំបាច់) ។**

អ្នកតំណាងរួមអាចត្រូវបានគេចាត់តាំងឡើងចំពោះតែក្នុងករណី ប្រសិនបើមានអ្នកដាក់ពាក្យសុំច្រើននាក់ និងប្រសិនបើពុំមានចាត់តាំងភ្នាក់ងារ : អ្នកតំណាងរួមត្រូវតែជាអ្នកណាម្នាក់នៃអ្នកដាក់ពាក្យសុំទាំងនោះ ។ បុគ្គលខាងក្រោមនេះ (អាចរួមមានអង្គភាពស្របច្បាប់ណាមួយ) ត្រូវបានចាត់តាំងជាភ្នាក់ងារ ឬ ជាតំណាងរួមដើម្បីអនុវត្ត ក្នុងនាមជាអ្នកដាក់ពាក្យសុំ (ម្នាក់ ឬ ច្រើននាក់) នៅចំពោះមុខមន្ត្រីកាន់កាប់បញ្ជី ។

ឈ្មោះ និង អសយដ្ឋានរួមទាំងលេខកូដប្រៃសណីយ៍របស់ភ្នាក់ងារ :..........................................................................................

..............................................................................................................................................................................................................

លេខទូរស័ព្ទ (រួមទាំងលេខកូដតំបន់) :..........................................................................................................................

លេខទូរសារ :.......................................................... អសយដ្ឋានអ៊ីម៉ែល:..........................................................................................

**ប្រអប់លេខ ៦**

**ការធ្វើអាជីវកម្ម**

☐ ការធ្វើអាជីវកម្មតាមទ្រង់ទ្រាយណាមួយនៅលើពិភពលោកតិចជាង ២ (ពីរ) ឆ្នាំ

☐ ការធ្វើអាជីវកម្មតាមទ្រង់ទ្រាយណាមួយនៅលើពិភពលោកលើសពី ២ (ពីរ) ឆ្នាំ

នៅទីកន្លែងណា/ប្រទេសណា នៅលើពិភពលោក (ប្រសិនបើមាន) :

..............................................................................................................................................................................................................................

..............................................................................................................................................................................................................................

..............................................................................................................................................................................................................................

**ប្រអប់លេខ ៧**

**សេចក្តីអះអាងអំពីអាទិភាព (ប្រសិនបើមាន)** ។ សូមអះអាងអំពីអាទិភាពនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនដូចតទៅ ៖

| ប្រទេស ឬការិយាល័យដែលបានដាក់សំណុំលិខិតស្នើសុំ : ( ប្រសិនបើសំណុំលិខិតស្នើសុំដែលបានដាក់មុន ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវបញ្ជាក់អំពីឈ្មោះការិយាល័យ និង ឈ្មោះប្រទេសដែលសំណុំលិខិតស្នើសុំនោះបានដាក់) : | កាលបរិច្ឆេទសុំចុះបញ្ជី ( ថ្ងៃ.ខែ.ឆ្នាំ) | លេខសំណុំលិខិតស្នើសុំ | និមិត្តសញ្ញានៃចំណាត់ថ្នាក់អន្តរជាតិរបស់គំនូរបង្ហាញនៃសៀវភៅគំរូបង្រួម |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |

លិខិតបញ្ជាក់អំពីសំណុំលិខិតស្នើសុំដែលបានដាក់មុន

☐ ត្រូវបានភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំនេះ ☐ ត្រូវបានផ្តល់ជូនក្នុងរយៈពេលបួន(៤)ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំ

**ប្រអប់លេខ ៨**

**ការត្រួតពិនិត្យឯកសារ(ត្រូវបំពេញដោយអ្នកដាក់ពាក្យសុំ)**

| សំណុំលិខិតស្នើសុំនេះរួមមាន : | សំណុំលិខិតស្នើសុំត្រូវមានឯកសារភ្ជាប់មកជាមួយដូចខាងក្រោម : |
|---|---|
| ១. ពាក្យសុំ ................................................ សន្លឹក | ១. លិខិតប្រគល់សិទ្ធិដោយឡែក / ចាត់តាំងភ្នាក់ងារតំណាង |
| ២. គំនូរបង្ហាញ ................................................ សន្លឹក | ២. លិខិតថតចម្លងនៃការប្រគល់សិទ្ធិទូទៅ |
| ៣. រូបថត/គំនូសតាង................................................ សន្លឹក | ៣. សេចក្តីថ្លែងបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ |
| | ៤. សេចក្តីថ្លែងបញ្ជាក់អំពីការបង្ហាញឱ្យគេដឹងមួយចំនួនដែលមិនយកជាបានការ |
| | ៥. ឯកសារអាទិភាព ( សូមមើលប្រអប់លេខ ៧) |
| | ៦. លិខិតបញ្ជាក់នៃសំណុំលិខិតស្នើសុំដំបូង |
| **សរុប** : ................. សន្លឹក | ៧. សេចក្តីបកប្រែជាភាសាអង់គ្លេសនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគេដែលការអះអាងអាទិភាពត្រូវបានយកធ្វើជាមូលដ្ឋាន |
| | ៨. វិក័យបត្រនៃការបង់ប្រាក់ |
| គំនូរលេខ.........................................នៃគំនូសបង្ហាញ | ៩. ឯកសារផ្សេងៗ ( សូមបញ្ជាក់) |

| | |
|---|---|
| (ប្រសិនបើមាន) ត្រូវបានស្នើសុំភ្ជាប់ទៅនឹងខ្លឹមសារសង្ខេប<br>ដើម្បីធ្វើការផ្សព្វផ្សាយ ។ | |

**ប្រអប់លេខ ១០**

**ហត្ថលេខាអ្នកដាក់ពាក្យសុំ ឬត្រាក់ខារ ព្រមទាំងត្រា ឈ្មោះ**

ហត្ថលេខា * .................................................................................... ..............................

(កាលបរិច្ឆេទ)

*ដាក់ឈ្មោះនៅក្រោមហត្ថលេខា

ប្រសិនបើពាក្យសុំនាពេលបច្ចុប្បន្នត្រូវបានចុះហត្ថលេខាដោយភ្នាក់ងារម្នាក់ តំណាងឱ្យអ្នកដាក់ពាក្យសុំ នោះចាំបាច់ត្រូវមានលិខិតបញ្ជាក់ប្រគល់សិទ្ធិដោយឡែកមួយក្នុងការចាត់តាំងភ្នាក់ងារនោះ ដែលចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ។ ប្រសិនបើមានដូចករណីនេះ សំណូមពរឱ្យប្រើលិខិតប្រគល់សិទ្ធិទូទៅមួយ (ដែលតំកល់ទុកនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម) លិខិតថតចម្លងនៃលិខិតប្រគល់សិទ្ធិត្រូវតែភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំនេះ ។

**ត្រូវបំពេញដោយមន្ត្រីកាន់កាប់បញ្ជី**

១. កាលបរិច្ឆេទនៃការទទួលការកែតម្រូវ ឬកាលបរិច្ឆេទនៃការទទួលឯកសារដែលបានដាក់ក្រោយគេសម្រាប់ការបំពេញឱ្យគ្រប់គ្រាន់នូវសំណុំលិខិតស្នើសុំ :

២. កាលបរិច្ឆេទទទួលកម្រៃ :..........................................................................................................................

ប្រអប់បន្ថែម ចូរប្រើប្រអប់នេះក្នុងករណីដូចតទៅ :

(១) ប្រសិនបើមានគ្នាច្រើនជាងចំនួនបីនាក់ ត្រូវបានជាប់ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំនិង / ឬអ្នកបង្កើតស្នាដៃ : ក្នុងករណីនេះចូរសរសេរប្រអប់បន្ថែមលេខ 3 និង បញ្ជាក់ឱ្យដឹងសម្រាប់បុគ្គលបន្ថែមម្នាក់ៗនូវប្រភេទពត៌មានដូចគ្នា ដូចដែលបានស្នើសុំឱ្យបំពេញនៅក្នុងប្រអប់លេខ ៣។

(២) ប្រសិនបើមានសំណុំលិខិតស្នើសុំអះអាងអាទិភាពលើសពីប្រាំឡើងទៅ : ក្នុងករណីនេះចូរបញ្ជាក់ក្នុងការបន្តរបស់ប្រអប់លេខ ៧ និងបញ្ជាក់បន្ថែមលើសំណុំលិខិតស្នើសុំដែលបានដាក់មុនគេនីមួយៗនោះនូវប្រភេទពត៌មានដូចគ្នា ដូចដែលបានតម្រូវឱ្យបំពេញនៅក្នុងប្រអប់លេខ ៧ ។

(៣) ប្រសិនបើនៅក្នុងប្រអប់ទាំងនោះគ្មានប្រអប់ទំនេរគ្រប់គ្រាន់សម្រាប់ផ្តល់ពត៌មាន ក្នុងករណីដូចនេះសូមសរសេរប្រអប់បន្តលេខ (ចូរសរសេរដាក់លេខនៃប្រអប់) ហើយសូមផ្តល់ពត៌មានក្នុងរបៀបដូចគ្នាដែលបានតម្រូវឱ្យបំពេញ ដោយយោងទៅតាមបញ្ហាដែលត្រូវអធិប្បាយនៅក្នុងប្រអប់ដែលពុំមានកន្លែងគ្រប់គ្រាន់នោះ ។